# សុន្ទរកថា

# ឯកឧត្តមអៀងមូលីទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

# ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# ក្នុងពិធីបើកកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៥

*សាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រីថ្ងៃទី១១ខែវិច្ឆិកាឆ្នាំ២០១៥*

- ឯកឧត្តមលោកជំទាវរដ្ឋលេខាធិការអនុរដ្ឋលេខាធិការតំណាងក្រសួង ស្ថាប័នជាសមាជិកសមាជិកា នៃកិច្ចប្រជុំពេញអង្គរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តមលោកជំទាវជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត
- ឯកឧត្តមលោកជំទាវលោកលោកស្រីជាថ្នាក់ដឹកនាំនិងមន្ត្រីនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- លោកលោកស្រីភ្ញៀវជាតិ និងអន្តរជាតិ

ជាបឋមខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅនិងថ្លែងអំណរគុណជាអនេកជូនចំពោះឯកឧត្តមលោកជំទាវលោកលោកស្រីដែលបានឆ្លៀតឱកាសដ៏មមាញឹកអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ឆ្នាំ២០១៥ ដ៏មានសារៈសំខាន់នាពេលនេះ។

ដូចដែលឯកឧត្តមអគ្គលេខាធិការបានលើកឡើងកិច្ចប្រជុំនាថ្ងៃនេះ នឹងផ្តោតលើគោលបំណងសំខាន់ៗបីគឺ ទី១). ពិនិត្យមើលលទ្ធផល សម្រេចបាន និងឧបសគ្គនៅ៦ខែចុងក្រោយ ទី២). ផ្តល់ការអនុមតិជាផ្លូវការលើផែនការយុទ្ធសាស្រ្តជាតិ និង ទី៣). ពិនិត្យអនុមតិលើកទិសដៅគោលនយោបាយសំខាន់ៗ ឆ្ពោះទៅរកចីរភាពនៃការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការរាលដាលមេរោគអេដស៍។

**ឯកឧត្តមលោកជំទាវលោកលោកស្រី!**

ដើម្បីជាទុនក្នុងការពិភាក្សាមុននឹងអនុម័តទិសដៅគោលនយោបាយចម្បងៗ ខ្ញុំសូមអនុញ្ញាតិយកឱកាសដ៏ថ្លៃថ្លានេះ សរុបត្រួសៗនូវស្ថានភាពនៃការរាលដាលមេរោគអេដស៍/ជំងឺអេដស៍និងលទ្ធផលនៃការឆ្លើយតបរហូតមកដល់ពេលនេះព្រមទាំងកិច្ចខិតខំប្រឹងប្រែងចម្បងៗរបស់យើងក្នុង៦ខែចុងក្រោយ ដូចខាងក្រោម៖

## ១. ស្ថានភាពរាលដាលនិងលទ្ធផលនៃការឆ្លើយតប

- អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុពី១៥-៤៩ឆ្នាំ បានបន្តធ្លាក់ចុះមក 0.៦% រហូតដល់ឆ្នាំ២០១៥នេះ ជាមួយនឹងការរំពឹងថានឹងបន្តធ្លាក់ចុះទៀតនៅឆ្នាំខាងមុខ បើយោងតាមនិទស្សន៍វិទ្យាសាស្ត្រ។
- ការឆ្លងថ្មីនៅបន្តកើតមានប្រហែល ២នាក់ក្នុង១ថ្ងៃ ហើយរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍សកលលោកឆ្នាំ២០១៥ (GARPR ២០១៥)បានបង្ហាញនូវចំណុចដែលទាមទារនូវការយកចិត្តទុកដាក់ជាប្រចាំមួយចំនួន ដូចជា៖
  ក).មូលហេតុចម្បងនៃការឆ្លងនៅតែតាម
  រយៈការរួមភេទ(មានដល់ជាង៨០ភាគរយនៃករណីឆ្លងថ្មី)
  ខ). អត្រាផ្ទុកមេរោគអេដស៍នៅតែខ្ពស់ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខបីគឺក្រុមបុគ្គលិកបម្រើសេវាកំសាន្តសប្បាយ ក្រុមបុរសស្រលាញ់បុរស និងក្រុមអ្នកប្រើប្រាស់គ្រឿងញៀន
  គ).កម្រិតយល់ដឹងពីការបង្ការការឆ្លងមេរោគអេដស៍ក្នុងចំនោមយុវវ័យ (ដែលមានចំនួនច្រើន) នៅទាបនៅឡើយ (៣៩.៦%: CDHS ២០១៤) ទោះអត្រាផ្ទុកមេរោគអេដស៍មានត្រឹម 0.១% (NMCH ២០១៤)
  ឃ).ឧបទ្ទវហេតុនៃការឆ្លងមេរោគអេដស៍ នៅឃុំរកា ខេត្តបាត់ដំបង ទោះយើងអាចគ្រប់គ្រងបាននាពេលនេះ គឺជាព័ត៌មានសំខាន់មួយបញ្ជាក់ថា អាចនៅមានប្រភពនៃការឆ្លងមេរោគអេដស៍ខ្លះដែលយើងចាប់មិនទាន់បានហើយកត្តាប្រឈមនៃការប្រើប្រាស់ម្ជុលមិនស្អាត និងចលនាប្រជាជនចល័តត្រូវតែរៀបចំឆ្លើយតប។
- អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូនគឺបានធ្លាក់ចុះប្រកបដោយការជឿជាក់ថាកម្ពុជានឹងអាចចូលរួមជាមួយពិភពលោក ក្នុងការកាត់បន្ថយទាំងស្រុងនូវការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅត្រឹមឆ្នាំ២០២០។
- ការថែទាំព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានបន្តគ្របដណ្តប់រហូតដល់ទៅ៧៨.៩% ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ ដែលត្រូវការឱសថប្រឆាំងមេរោគអេដស៍ ជាមួយនឹងក្តីសង្ឃឹមពីលទ្ធភាពក្នុងការសម្រេចបានគោលដៅសាកលនៃការគ្របដណ្តប់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ៩០% នៅឆ្នាំ២០២០។
- តាមការប៉ាន់ប្រមាណ យើងនៅបន្តមានអ្នកស្លាប់ទាក់ទងនឹងជំងឺអេដស៍ប្រហែល៥ទៅ៦នាក់ក្នុង១ថ្ងៃ

ដែលទាមទារការពង្រឹងគុណភាពសេវាថែទាំព្យាបាល សេវាគាំទ្រសង្គមសេដ្ឋកិច្ច និងលទ្ធភាពបង្កើនប្រាក់ចំណូលនៃអ្នកផ្ទុកមេរោគអេដស៍ផ្ទាល់ ដែលជាគន្លឹះជំរុញនូវប្រសិទ្ធិភាពនៃការព្យាបាល។

- ការគាំទ្រសង្គមសេដ្ឋកិច្ចដល់គ្រួសារក្រីក្រនៃអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ កុមារកំព្រា ឬកុមាររងគ្រោះដោយសារជំងឺអេដស៍នៅមានខ្វះក្រោមកម្មវិធីតូចៗនៃអង្គការសង្គមស៊ីវិល និងការងារមនុស្សធម៌របស់កាកបាទក្រហមកម្ពុជា បន្ទាប់ពីមានការបញ្ចប់កម្មវិធីគាំទ្រស្បៀងនៅចុងឆ្នាំ២០១២។ តែអត្រាទទួលបានការគាំទ្រនេះមានកម្រិតទាបត្រឹម ៨.៥៥% តាមតួលេខអង្គការខាន់ណា ឆ្នាំ២០១៤ (GARPR ២០១៥)។

## ២. គោលនយោបាយធំៗដែលសម្រេចបាននា៦ខែចុងក្រោយ

- រាជរដ្ឋាភិបាលបានអនុម័ត សំណើកម្មវិធីឆ្លើយតបរយៈពេលវែងសម្រាប់ឧបទ្ទវហេតុនៅឃុំរកាខេត្តបាត់ដំបង
- បានរៀបចំនិងដាក់ជូនរាជរដ្ឋាភិបាលពិចារណា ផែនការសំណើថវិកាជាតិ៤លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ការគាំទ្រស្បៀងអាហារដល់អ្នកផ្ទុកមេរោគអេដស៍ក្រីក្រ ការបង្កើតគោលនយោបាយគន្លឹះៗសម្រាប់គាំទ្រការបញ្ជៀបការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ទៅថ្នាក់ក្រោមជាតិនិងវិស័យអភិវឌ្ឍពាក់ព័ន្ធ ព្រមទាំងការពង្រឹងតួនាទីថ្នាក់ក្រោមជាតិក្នុងការដឹកនាំការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍និងការបង្កើតបរិយាកាសគាំទ្រ បន្ថែមលើការអនុម័តកន្លងមករបស់រាជរដ្ឋាភិបាលចំពោះការចូលរួមទិញឱសថប្រឆាំងមេរោគអេដស៍១លានក្នុង១ឆ្នាំ និងការទិញស្រោមអនាម័យ១សែនក្នុង១ឆ្នាំ។
- បានចាប់ផ្តើមពិភាក្សារកកិច្ចសហការឆ្លងព្រំដែនជាមួយប្រទេសថៃលើការងារឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមប្រជាជនចល័ត។
- បានដាក់បញ្ចូល ព័ត៌មានស្តីពីស្ថានភាពរាលដាលមេរោគអេដស៍/ជំងឺអេដស៍ ទិសដៅយុទ្ធសាស្ត្រនៃការឆ្លើយតបប្រកបដោយចីរភាព និងតម្រូវការការវិនិយោគសាធារណៈជាអាទិភាព ទៅក្នុង គោលនយោបាយជាតិប្រជាជន និងរបាយការណ៍វឌ្ឍនភាពនៃការសម្រេចគោលដៅអភិវឌ្ឍសាកល ដើម្បីស្វែងរកការគាំទ្រជាគោលនយោបាយនិងថវិកាពីរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ។
- បានចូលរួមកិច្ចប្រជុំបណ្តាញក្រុមការងាររាជរដ្ឋាភិបាល/ដៃគូអភិវឌ្ឍ ពិនិត្យត្រៀមរៀបចំធ្វើមូលដ្ឋានូបនីយកម្ម នូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដែលទើបអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ

សម្រាប់ជាឱកាសស្វែងរកការគាំទ្រដល់កម្មវិធីឆ្លើយតបមេរោគអេដស៍ក្នុង១៥ឆ្នាំខាងមុខផងដែរ។

- បានសម្របសម្រួលនូវកិច្ចប្រជុំអន្តរក្រសួង (អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល កម្មវិធីអេដស៍ របេង និងគ្រុនចាញ់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ) ស្វែងរកដំណោះស្រាយបញ្ហា DSAសម្រាប់មន្ត្រីរាជកាតួនាទី GFA
និងស្ថានភាពនៃការប្រើប្រាស់បុគ្គលិកកិច្ចសន្យានាពេលខាងមុខក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានថ្មី នៃមូលនិធិសាកល។
- បានគាំទ្រនិងចូលរួមការបង្កើតនិយាមបែបបទអនុវត្តការងារក្នុងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន។
- បានសហការជាមួយ USAID រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីនិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីវាស់ស្ទង់ពីលទ្ធភាពរបស់យើងក្នុងការបន្តនិរន្តរភាពនៃការគ្រប់គ្រងការរាលដាលមេរោគអេដស៍ ពេលដៃគូអភិវឌ្ឍកាត់បន្ថយជំនួយនិងចាកចេញ ដែលជាមូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រត្រៀមលក្ខណៈទទួលខុសត្រូវ។
- រៀបចំចុះកិច្ចសន្យាគម្រោងហិរញ្ញប្បទានថ្មីនៃមូលនិធិសកលសម្រាប់ឆ្នាំ២០១៥ទៅ២០១៧ និងរៀបចំផែនការធ្វើឲ្យសម្រេចគោលដៅយុទ្ធសាស្ត្រ ៩០ - ៩០ - ៩០។
- នឹងចែករំលែក យុទ្ធសាស្ត្រឆ្ពោះទៅរកចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍ របស់កម្ពុជានាកិច្ចប្រជុំអន្តរជាតិស្តីពីជំងឺអេដស៍នៃតំបន់អាស៊ីនិងប៉ាស៊ីហ្វិក សប្តាហ៍ក្រោយ នៅប្រទេសបង់ក្លាដែស ដែលអាចជាឱកាសទាក់ទាញការយកចិត្តទុកដាក់ពីដៃគូអភិវឌ្ឍជួយយើងបន្ត ក្នុងការផ្ទេរការទទួលខុសត្រូវជាម្ចាស់ទាំងស្រុងប្រកបដោយភាពរលូន។
- ត្រៀមជំរុញ ឲ្យមានការគាំទ្រថ្នាក់តំបន់ លើការឆ្លើយតមេរោគអេដស៍/ជំងឺអេដស៍ឆ្លងព្រំដែន ក្នុងកិច្ចប្រជុំក្រុមការងារអភិវឌ្ឍន៍ធនធានមនុស្សមហាអនុតំបន់ទន្លេមេគង្គ នៅខេត្តសៀមរាប សប្តាហ៍ក្រោយ។
- នឹងរៀបចំទិវាអេដស៍ពិភពលោកនៅថ្ងៃ៣០ វិច្ឆិកា ខាងមុខដើម្បីជំរុញការយកចិត្តទុកដាក់និងការគាំទ្រជាសាធារណៈក្នុងការទប់ស្កាត់ការឆ្លងរាលដាលមេរោគអេដស៍។
- ព្រមទាំងមានអន្តរាគមន៍មួយចំនួនទៀតធ្វើឡើងដោយស្ថាប័នជាសមាជិកទាំងឡាយដែលខ្ញុំសូមអនុញ្ញាតិមិនរៀបរាប់ទាំងអស់ទេ។

**ឯកឧត្តមលោកជំទាវលោកលោកស្រី!**

ជាទស្សនវិស័យ យើងប្តេជ្ញាចិត្តចូលរួមជាមួយអង្គការសហប្រជាជាតិក្នុងការសម្រេចមហិច្ឆតាដ៏ធំធេងនៃការលុបបំបាត់ការឆ្លងមេរោគអេដស៍ថ្មីនៅឆ្នាំ២០២០ តាមរយៈការឆ្ពោះទៅសម្រេចគោលដៅគោលដៅយុទ្ធសាស្ត្រ ៩០ - ៩០ - ៩០ (៩០% នៃអ្នកផ្ទុកមេរោគអេដស៍នឹងដឹងពីស្ថានភាពផ្ទុក

មេរោគអេដស៍របស់ខ្លួន ៩០ % នៃមនុស្សដែលបានធ្វើរោគវិនិច្ឆ័យឃើញមានផ្ទុកមេរោគអេដស៍ បានទទួលការព្យាបាលដោយថ្នាំប្រឆាំងវីរុសប្រកបដោយចីរភាព៩០%នៃប្រជាជនទាំងអស់ដែលបាន ទទួលការព្យាបាល ដោយថ្នាំប្រឆាំងងវីរុសនឹងគ្មានវីរុសក្នុងឈាម ) នៅឆ្នាំ២០២០ ហើយធានាថា គ្មាននរណាម្នាក់ត្រូវបានទុកចោលមិនទទួលការថែទាំនិងព្យាបាលឡើយ។ យ៉ាងណាក៏ដោយ ក្នុង បរិបទប្រែប្រួលនៃស្ថានភាពរាលដាលមេរោគអេដស៍ និងស្ថានភាពហិរញ្ញទាននាពេលនេះ ទាមទារ នូវការផ្លាស់ប្តូររបស់យើងទាំងយុទ្ធសាស្រ្តនៃការឆ្លើយតប ទាំងអាទិភាពនៃការផ្តល់ហិរញ្ញវត្ថុវិនិយោគ ព្រមទាំងរបៀបរបបការងារះ

- ជាមួយនឹងការរាលដាលបែបប្រមូលផ្តុំ អន្តរាគមន៍ឆ្លើយតបត្រូវតែកាន់តែមានលក្ខណៈផ្តោតជាងមុន (more targeted interventions) ដោយប្រមូលផ្តុំកំលាំងលើចំណុចជាបញ្ហា។
- នៅពេលហិរញ្ញប្បទានជំនួយក្រៅប្រទេសធ្លាក់ចុះ បន្ទុកទទួលខុសត្រូវក្នុងនាមជាម្ចាស់ត្រូវធ្លាក់មកលើរាជរដ្ឋាភិបាល ហើយការបង្កើនចំណាយថវិកាជាតិសម្រាប់ការឆ្លើយតបនឹងការរាលដាលមេរោគអេដស៍/ជំងឺ អេដស៍ ត្រូវចាត់ទុកដូចជាការវិនិយោគរបស់ជាតិ ដើម្បីថែរក្សាផលិតភាពក្នុងការចូលរួម អភិវឌ្ឍសេដ្ឋកិច្ច និងបង្ការវិបត្តិសង្គមដែលអាចកើតឡើងពីផលប៉ះពាល់នៃការរាលដាលមេរោគអេដស៍និងជំងឺ អេដស៍។ការបង្កើនការទទួលខុសត្រូវនេះ នឹងត្រូវធ្វើឡើងតាមការដាក់បញ្ចូលអាទិភាព ការងារវិស័យអេដស៍ ទៅក្នុងផែនការវិនិយោគជាតិបីឆ្នាំរំកិល នៃផែនការយុទ្ធសាស្រ្ត អភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល។
- ដោយថវិកាហិរញ្ញប្បទានជំនួយក្រៅប្រទេសធ្លាក់ចុះលែងអនុញ្ញាតិឲ្យអង្គការសង្គស៊ីវិលដំណើ រទូលំទូលាយបាន រដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិនិងអាជ្ញាធរមូលដ្ឋាននឹងក្លាយជាតួអង្គ សំខាន់ក្នុងការទទួលយកការងារឆ្លើយតបនេះប្រកបដោយភាពជាម្ចាស់។ ក្នុងន័យនេះ អាជ្ញាធរមូលដ្ឋាននឹងត្រូវធ្វើការជិតស្និតជាមួយមណ្ឌលសុខភាពឬមន្ទីរពេទ្យបង្អែក។ ពេល មន្ត្រីនៃប្រព័ន្ធសុខាភិបាលទទួលខុសត្រូវលើការថែទាំព្យាបាល អាជ្ញាធរមូលដ្ឋានមាននាទី គ្រប់គ្រងអន្តរាគមន៍បង្ការ តាមរយៈការផ្តល់ការអប់រំ ការបញ្ជូនក្រុមប្រឈមទៅទទួលសេវា សុខភាពការបង្កបរិយាកាសគាំទ្រ និងផ្តល់ការគាំពារសង្គម។
- វិស័យអភិវឌ្ឍពាក់ព័ន្ធមួយចំនួនមាននាទីសំខាន់ក្នុងការជួយបង្កើនស៊ីនែរស៊ីដល់ភារកិច្ចរបស់វិ ស័យសុខាភិបាលនិងអាជ្ញាធរមូលដ្ឋាន តាមរយៈការបន្តជំរុញការអនុវត្តគោលនយោបាយ ៧ចំណុចនៃ ស.ជ.ណ. របស់រាជរដ្ឋាភិបាលដែលដាក់ចេញកាលពីខែធ្នូ ឆ្នាំ២០១៣។ ជាអាទិ៍ះ
    - ការជំរុញអោយមានការកែសម្រួលឧបករណ៍វាយតម្លៃ និងផ្តល់ប័ណ្ណក្រីក្រដោយគិតគូរដល់បញ្ហាអេដស៍ (HIV-sensitive ID Poor

Assessment Tool) និងការបង្កើតកូដថវិកាសម្រាប់ការងារអេដស៍ក្នុងខ្ទង់ថវិកាឃុំសង្កាត់ គឺជាអាទិភាពដែលត្រូវពិចារណា ដើម្បីអាច ឲ្យអ្នកផ្ទុកមេរោគអេដស៍ទទួលបាននូវអន្តរាគមន៍ចាំបាច់ក្នុងប្រព័ន្ធសុវត្ថិភាពសង្គម។

- ការឆ្លើយតបនឹងមេរោគអេដស៍នៅគ្រឹះស្ថានការងារដែលកំពុងដឹកនាំយ៉ាងសកម្មដោយក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានកោតសរសើរ និងលើកទឹកចិត្តបន្ត ។ល។

- សមាជិកសមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងមូល មានភារកិច្ច ចម្បង ក្នុងការពិនិត្យលើកសំណើ និងអនុម័តនូវគោលនយោបាយគាំទ្រ បង្កើតនិយាមបែបបទអនុ វត្តការងារ ព្រមទាំងរៀបចំនិងពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធក្នុងដំណើការបញ្ច្រៀបការទទួលខុសត្រូវការគ្រប់គ្រងការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ទៅថ្នាក់ក្រោមជាតិ និងវិស័យអភិវឌ្ឍពាក់ព័ន្ធ ជាពិសេសក្នុងផែនការវិនិយោគនិងអភិវឌ្ឍឃុំសង្កាត់។
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិមាននាទីរៀបចំផែនការតម្រង់ទិសការងារ កម្មវិធីហ្វឹកហ្វឺនបង្កើនសមត្ថភាព និងពង្រឹងក្របខ័ណ្ឌតាមដានវាយតម្លៃការអនុវត្ត។
- ក្នុងតំណាក់កាលនេះ ទាមទារការយកចិត្តទុកដាក់ខ្លាំងពីគ្រប់ដៃគូពាក់ព័ន្ធ ជាពិសេសដៃគូអភិវឌ្ឍនិងអង្គការសង្គមស៊ីវិលក្នុងការផ្ទេរចំណេះដឹង ជំនាញនិងសមត្ថភាពដល់អាជ្ញាធរមូលដ្ឋានដែលនឹងទទួលយកការងារនេះ។

ការប្រើប្រាស់យន្តការដែលមានស្រាប់បែបនេះ នឹងអនុញ្ញាតឲ្យយើងអាចធ្វើអន្តរាគមន៍បានច្រើនប្រកបដោយប្រសិទ្ធិភាពខ្ពស់ជាមួយនឹងការចំណាយកម្រិតទាប (do more with less) ពង្រឹងភាពជាម្ចាស់ប្រទេស (country ownership) និងបង្កើនគណនេយ្យភាពក្នុងនាមជាស្ថាប័នសាធារណៈចំពោះសង្គម ព្រមទាំងធានាបាននូវនិរន្តរភាពនៃការឆ្លើយតប(sustainable response)។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមសំដែងជាថ្មីម្តងទៀតនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះស្ថាប័នអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍទាំងឡាយដែលបាននិងកំពុងបន្តគាំទ្រប្រទេសកម្ពុជាទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ដែលធ្វើអោយសម្រេចបានជោគជ័យដ៏ធំធេងនូវការទប់ស្កាត់ការឆ្លងរាលដាលមេរោគអេដស៍បានដូចពេលបច្ចុប្បន្ននេះហើយយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាដៃគូទាំងឡាយនឹងមិនចាកចេញពីយើងដោយងាយៗ ដោយមិនបានជ្រោមជ្រែងយើងឲ្យសម្រេចបាននូវលទ្ធភាពបន្តនិរន្តភាពនៃការងារជាមុននោះទេ។

**ឯកឧត្តមលោកជំទាវលោកលោកស្រី ជាទីរាប់អាន!**

ក្នុងដំណើរការនៃកិច្ចប្រជុំ ខ្ញុំសូមលើកទឹកចិត្តឯកឧត្តមលោកជំទាវលោកលោកស្រី ជួយពិនិត្យចូលរួមផ្តល់គំនិត និងផ្តល់ការអនុម័តលើពង្រាងសេចក្តី សម្រេចចិត្តនៃអង្គប្រជុំ ដែលនឹងក្លាយជាត្រីវិស័យនិងឧបករណ៍វាស់ស្ទង់ដំណើររបស់យើងទៅ៦ខែខាងមុខ ក្នុងវឌ្ឍនភាពនៃការឆ្ពោះទៅរកចីរភាពនៃការទទួលខុសត្រូវឆ្លើយតបនឹងការរាលដាលមេរោគអេដស៍។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ ឯកឧត្តមលោកជំទាវលោកលោកស្រី និងសូមប្រកាសបើកកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៥ ចាប់ពីពេលលនេះតទៅ៕

**សូមអរគុណ**